# ហេតុអ្វីបានជាមនុស្សគ្រប់គ្នាចង់បាន
## សេចក្ដីសុខសាន្ត និងព្រះពរ



## ក្នុងជីវិត?



ព្រះគម្ពីរថា ៖

**សេចក្ដីសុចរិតរមែងលើកដំកើងនគរ តែអំពើបាបជាគួរខ្មាសដល់សាសន៍ណាៗ ក៏ដោយ។** សុភាសិត១៤:៣៤

យើងទាំងអស់គ្នាដឹងថា អំពើល្អនឹងសេចក្ដីសុចរិត នាំឲ្យសាសន៍យើង ឬគ្រួសារណាមួយ មានតំលៃ ហើយមានកិត្តិយស។ សាសន៍ណា ឬគ្រួសារណាដែលមានអំពើបាបគួរខ្មាសវិញ។

ព្រះគម្ពីរព្រះយេស៊ូវថា ៖

**ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះជាម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវៗ**

**ចូរគោរពប្រតិបត្តិដល់មាតាបិតាខ្លួនៗ** អេភេសូរ៦:១-២

វិន័យធម៌នេះ យើងទទួលស្គាល់ទាំងអស់គ្នាថា ល្អហើយគួរធ្វើតាម។ មានវិន័យធម៌ផ្សេងៗ ទៀតដែរ ដែលយើងគួរតែគោរពដូចជា ចូរឲ្យស្មោះត្រង់និងប្តីប្រពន្ធ កុំផិតក្បត់ឡើយ ។ល។



ព្រះគម្ពីរព្រះយេស៊ូវថា **ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្តីវឹកវរទេ គឺទ្រង់ជាព្រះនៃសេចក្តីសុខសាន្តវិញ** កូរិនថូសទី១ ១៤:៣៣

ព្រះដ៏ពិតដែលបានបង្កើតរបស់សព្វសារពើនូវពិភពលោកនេះ គឺព្រះយេស៊ូវ ទ្រង់មិនមែនជាព្រះនៃសេចក្តីវឹកវរ ការរងទុក្ខ ឬអំពើបាបឡើយ។ ទ្រង់ជាព្រះនៃសេចក្តីស្រឡាញ់ យុត្តិធម៌ និងសេចក្តីសុខសាន្តវិញ។

ព្រះគម្ពីរថា **ក្រិត្យវិន័យរបស់ព្រះបានទុកក្នុងចិត្តគេហើយ បញ្ញាចិត្តគេក៏ធ្វើបន្ទាល់ឲ្យ ហើយគំនិតគេជួនកាលប្រកាន់ទោស ជួនកាលដោះសារគ្នាទៅវិញទៅមក** រ៉ូម២:១៥

នៅពេលដែលព្រះយេស៊ូវបានបង្កើតមនុស្ស ទ្រង់បានទុកក្រិត្យវិន័យរបស់ព្រះក្នុងចិត្តរបស់គេ។ ហេតុនោះហើយមនុស្សលោកទាំងអស់ ទោះបីជាសាសន៍ណា ឬកាន់សាសនាមួយណាក៏ដោយ គ្រប់គ្នាដឹងថា យើងគួរតែដើរតាមផ្លូវល្អ កុំធ្វើបាប។ បើប្រព្រឹត្តបាប បញ្ញាចិត្តប្រកាន់ទោស។



**ព្រះយេស៊ូវ មានបន្ទូលថា គ្មានសេចក្តីសុខសោះដល់ពួកមនុស្សដែលប្រព្រឹត្តអាក្រក់** អេសាយ៤៨:២២

លទ្ធផលនៃអំពើបាបរបស់យើង គឺគ្មានសេចក្តីសុខក្នុងជីវិតទេ។ អស់អ្នកណាដែលមានបាបមានការរងទុក្ខ ហើយគ្មានសេចក្តីសុខឡើយ។ អស់ទាំងការខ្វះខាតក្នុងសេចក្តីស្រឡាញ់ ឈ្លោះគ្នា ការស្អប់ លោភលន់ អំពើពុករលួយ មិនស្មោះត្រង់ មិនស្តាប់មាតាបិតាខ្លួន ការរមិលគុណនូវចំពោះព្រះយេស៊ូវដែលបានបង្កើតខ្លួន ហើយអំពើបាបក្នុងចិត្ត ។ល។ នាំឲ្យមនុស្សលោកឲ្យគ្មានសេចក្តីសុខក្នុងជីវិត។

ព្រះគម្ពីរថា **គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់គ្មានផង។ គ្មានអ្នកណាដែលយល់ គ្មានអ្នកណា ដែលស្វែងរកព្រះៗ គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង** រ៉ូម៣:១០-១២

តើអ្នកមានសេចក្តីសុខក្នុងជីវិតទេ? ឥតមានទេ។ ទោះបើជាអ្នកមានលុយច្រើន កាន់តាមទំលាប់ សាសនាល្អ ខំប្រឹងកាន់សិល ឬថ្ងៃនេះមានសុខភាពល្អ ថ្ងៃក្រោយពិតជាមានការឈឺចាប់ ការបាត់បង់ ការឈ្លោះប្រកែកគ្នា គ្រោះថ្នាក់ ហើយការលំបាកផ្សេងៗ កើតឡើងរហូតដល់យើងចូលមរណៈភាព។ សេចក្តីសុខនៅលើផែនដីនេះត្រូវគេចពីយើងរហូត ពីព្រោះយើងទាំងអស់គ្នាជាអ្នកមានបាប ហើយកាន់តាមវិន័យធម៌របស់ព្រះមិនបាន។ កុំជឿពាក្យបោកប្រាស់ដែលថា ធ្វើបុណ្យច្រើនបានសេចក្តីសុខ ឬបើរកលុយបានមានទ្រព្យច្រើនអ្នកនឹងមានសេចក្តីសុខនោះទេ។



**រួចព្រះទ្រង់ទតគ្រប់ទាំងរបស់ដែល ទ្រង់បានធ្វើនោះក៏ឃើញថា**

**ទាំងអស់ជាការល្អប្រពៃ** លោកុប្បត្តិ១:៣១

កាលដើមដំបូង ពិភពលោករបស់ព្រះយេស៊ូវនេះល្អឥតខ្ចោះទេ។ មិនទាន់មានវត្ថុអាក្រក់ណា ការរងទុក្ខ ឬសេចក្ដីស្លាប់ទេ មានតែសេចក្ដីសុខសាន្ត។ បន្ទាប់មកលោកយាយលោកតាដំបូងវង្វេងពីព្រះ ហើយនាំអំពើអាក្រក់ចូលក្នុងលោកនេះតាមរយៈអំពើបាបរបស់គេ។

ព្រះគម្ពីរថា **កាលគេបានស្គាល់ព្រះ នោះគេមិនបានដំកើងទ្រង់ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ។ គេកើតមានគំនិត ឥតប្រយោជន៍វិញ ហើយចិត្តគេដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ។** រ៉ូម១:៣១

លោកអ្នកឃើញទេ? យាយតារបស់យើងនូវសម័យដើមបានវង្វេងពីព្រះដ៏ពិត។ គាត់បានរមិលគុណដល់ព្រះ អួតខ្លួន ហើយបង្កើតផ្លូវដើរដែលឥតប្រយោជន៍ហើយឥតយោបល់វិញ។ សេចក្ដីសុខសាន្តរបស់ព្រះបានចេញពីផែនដី ហើយការរងទុក្ខនឹងការអាក្រក់បានចូលមក ហើយយើងបានតាមគំរូរបស់គេ ត។ គ្នារហូតដល់ថ្ងៃនេះ។



ព្រះគម្ពីរថា **ព្រះយេស៊ូវទ្រង់មានបន្ទូលថា គ្មានសេចក្ដីសុខសោះ ដល់ពួកមនុស្ស ដែលប្រព្រឹតអាក្រក់** អេសាយ៤៨:២២

ជីវិតនេះពោរពេញទៅដោយការឈឺចាប់ ទាំងរូបកាយ ហើយខាងឯវិញ្ញាណនិងអារម្មណ៏របស់យើង។ មើលរូបភាពនេះ តើលោកអ្នកធ្លាប់មានអារម្មណ៏ដូចបុរសក្នុងរូបនេះទេ? ធ្លាប់! អារម្មណ៏គាត់យ៉ាងដូចម្ដេច? គាត់ឈឺផ្លូវចិត្ត អស់សង្ឃឹម ព្រួយបារម្ភ ស្ដាយ។ មនុស្សលោកទាំងអស់គឺដូចអ្នកក្នុងរូបនេះ ខាងឯផ្លូវចិត្ត និងវិញ្ញាណ ទោះបីជាមានឬក្រ ធំឬតូច ក្មេងឬចាស់។ ពីព្រោះអ្វី? យើងគ្មានព្រះដ៏ពិតជាអ្នកទីពឹង ហើយយើងពឹងលើខ្លួនឯង។ ព្រះយេស៊ូវមានបន្ទូលថា ៖

**ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យនោះមិនមែនដូចជា លោកីយឲ្យទេ កុំឲ្យចិត្តអ្នករាល់គ្នាថប់ប្បារម្ភ ឬភ័យឡើយ** យ៉ូហាន១៤:២៧

ពាក្យនេះមានន័យថា សេចក្ដីសុខសាន្តដ៏ពិតមកតាមព្រះពររបស់ទ្រង់ មិនមែនតាមផ្លូវដែលមនុស្សបង្កើតនោះទេ។ សេចក្ដីសុខសាន្តដ៏ពិតនោះ មិនដូចសេចក្ដីសុខសាន្តរបស់លោកីយដ៏មិនពិតនោះសោះ។ សេចក្ដីសុខរបស់ព្រះយេស៊ូវនាំឲ្យយើងទុកចិត្តលើព្រះអង្គ ហើយលែងព្រួយក្នុងជីវិត។



**ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ** យ៉ូហាន៣:១៦

លោកអ្នកជាអ្នកដែលមានទោសយ៉ាងធ្ងន់។ លោកអ្នកមិនបានកាន់តាមវិន័យធម្មដែលព្រះបានទុកក្នុងចិត្តរបស់អ្នក។ អ្នកមិនបានស្វែងរកព្រះ រមិលគុណព្រះ ហើយបានបន្តគំនិតឥតប្រយោជន៍ ដូចជាយាយតានៅសម័យដើម។ ព្រះអង្គត្រូវតែកាត់ទោសអំពើបាបរបស់លោកអ្នក ប៉ុន្តែទ្រង់ស្រឡាញ់លោកអ្នក ដូច្នេះព្រះយេស៊ូវ ជាព្រះរាជបុត្រា ទ្រង់បានបន្ទាបខ្លួនយាងចុះពីឋានសួគ៌ចាប់កំណើតជាមនុស្ស ដើម្បីបើកផ្លូវជួយសង្គ្រោះលោកអ្នកឲ្យរួចពីការរងទុក្ខវេទនាជាលទ្ធផលបាប ហើយទទួលជីវិតអស់កល្បជានិច្ចវិញ។

ព្រះយេស៊ូវមានបន្ទូលថា **ខ្ញុំប្រាប់សេចក្ដីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្ដីសុខសាន្តដោយសារខ្ញុំ នៅលោកីយនេះ នោះអ្នករាល់គ្នាមានសេចក្ដីវេទនាមែន ប៉ុន្តែត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយហើយ** យ៉ូហាន១៦:៣៣

បើសិនជាលោកអ្នកកែប្រែចិត្តទទួលជឿព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់លោកអ្នក ទ្រង់នឹងផ្ដល់សេចក្ដីសុខសាន្តដ៏ពិតដល់លោកអ្នក ប្រយោជន៍នឹងជួយអ្នកឲ្យទ្រាំសេចក្ដីវេទនានៅលោកីយនេះ ទាំងឲ្យជីវិតអស់កល្បជានិច្ចឲ្យលោកអ្នក ដើម្បីឡើងទៅនៅឋានសួគ៌ជាមួយព្រះអង្គនៅពេលដែលលោកអ្នកទទួលមរណៈភាព។